២_ធនាគារកសិករថៃ សាខាភ្នំពេញ ចំនួន ១.០០០ ដុល្លារអាមេរិក

៣_វិសាលធនាគារអន្តរជាតិ ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

៤_ធនាគារបាងកក សាខាភ្នំពេញ ចំនួន ១.០០០ ដុល្លារអាមេរិក

៥_ធនាគារកម្ពុជា ពាណិជ ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

៦_ធនាគារក្រុងថៃ ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

៧_ធននាគារកាណាឌីយ៉ា ចំនួន ១.០០០ ដុល្លារអាមេរិក

៨_ធនាគារសហពាណិជ ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

៩_ធនាគារសឹង្ហបូរី ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

១០_ធនាគារសកលពាណិជ ចំកាត់ ចំនួន ១.០០០ ដុល្លារអាមេរិក

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជាត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤*

# ២.សេចក្តីសំរេច

## សេចក្តីសំរេចលេខ ១៣៦ ស.ស.រ

## ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង

រាជរដ្ឋាភិបាលកម្ពុជា

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម របស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងមួយដែលមានសមាសភាពដូចខាងក្រោមនេះ ÷

-អភិបាលខេត្ត-ក្រុង ជាប្រធាន

-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ជាអនុប្រធាន

-ប្រធានគណៈកម្មការផែនការខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរកសិកម្មខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរអប់រំខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរសាធារណការខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរវប្បធម៌ខេត្ត-ក្រុង ជាសមាជិក

-ប្រធានមន្ទីរកិច្ចការនារីខេត្ត-ក្រុង ជាសមាជិក

-ប្រធានស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ជាសមាជិក

-អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ជាលេខាធិការអចិន្ត្រៃយ៍

ដោយឡែក តំណាងអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តនូវកម្មវិធីគំរោងការងារអភិវឌ្ឍន៍ ជនបទនៅតាមខេត្ត-ក្រុងក៏ត្រូវចូលរួមក្នុង គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ក្នុងឋានៈជាសមាជិកសង្កេតការណ៍ផងដែរ ។

**ប្រការ ២ :** គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង មានតួនាទីជាសេនាធិការជំនួយការអោយ " ក្រសួងអភិវឌ្ឍន៍ជនបទ " ដែលជាស្ថាប័នជំនាញទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ព្រមទាំងណែនាំអោយខេត្ត-ក្រុង ក្នុងការកសាងផែនការកម្មវិធីការងារអភិវឌ្ឍន៍ជនបទក្នុងក្របខ័ណ្ឌទូទាំងខេត្ត-ក្រុង ។

**ប្រការ ៣ :** គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង មានភារកិច្ចដូចតទៅ ÷

-ប្រមូលផ្តុំនូវទិន្នន័យ ពត៌មាន ស្តីពីស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ តាមជនបទរបស់ខេត្ត -ក្រុង ដើម្បីជាមូលដ្ឋានក្នុងការកំណត់អោយបាន ច្បាស់លាស់នូវភូមិ-ឃុំណា ដែលក្រីក្រជាងគេ មធ្យម និងមានធូរធារ ។

-ផ្អែកលើមូលដ្ឋានខាងលើ លើកផែនការការងារអភិវឌ្ឍន៍ជនបទ ដោយកំណត់ អាទិភាព លើកម្មវិធីគំរោងការងារ ទៅតាមសភាពជាក់ស្តែងនៃខេត្ត-ក្រុងនីមួយៗ ដើម្បីដាក់ជូនក្រសួង អភិវឌ្ឍន៍ជនបទពិនិត្យ អនុម័ត និងចាត់ចែងការអនុវត្តន៍ទៅតាម គោលការណ៍ និងបច្ចេកទេស ។

-ពង្រឹង និងបង្កើននូវចំណងសាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាង មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត- ក្រុង ព្រមទាំងអង្គការអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាលផ្សេងៗ ក្នុងគោលបំណងធ្វើអោយការកសាងផែនការការងារ អភិវឌ្ឍន៍ជនបទ នៅតាមខេត្ត-ក្រុងមានភាពងាយស្រួល និងទទួលបានជោគជ័យ ។

**ប្រការ ៤ :** រាល់លិខិតបទដ្ឋានណាដែលមានលក្ខណៈផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរខេត្ត-ក្រុង គ្រប់សមាសភាពដែលមានចែងក្នុងប្រការ ១ និងបណ្តាស្ថាប័នពាក់ព័ន្ធនានាត្រូវទទួលបន្ទុកអនុវត្តអោយមាន ប្រសិទ្ធភាពតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***